
Kids of Destiny®
Reaching the Next Generation
www.kidsofdestiny.org

## 3.10 ព្រះយេស៊ូវព្យាបាលមនុស្សច្រើនថែមទៀត

«ការព្យាបាលមនុស្សជាអ្វី ដែលព្រះយេស៊ូវទ្រង់បានធ្វើនៅគ្រប់ទីកន្លែង ដែលទ្រង់បានយាងទៅ។ ទ្រង់នឹងព្យាបាលរាង្គកាយរបស់ពួកគេ។ ទ្រង់ថែមទាំងព្យាបាល នូវគំនិតដ៏គ្រោះថ្នាក់របស់ពួកគេថែមទៀត ។ ប្រសិនបើអារក្ស (សត្រូវរបស់ព្រះ) បានបញ្ជូនវិញ្ញាណអាក្រក់ឱ្យចូលមនុស្សនោះ ពេលព្រះយេស៊ូវមានបន្ទូលថា "ចូរចេញទៅ!" ហើយអារក្សនឹងចាកចេញទៅ ។ ព្រះយេស៊ូវជាអ្នកជំនាញក្នុងការព្យាបាល! ពេលខ្លះព្រះយេស៊ូវ ទ្រង់បានព្យាបាលមនុស្សនៅក្នុងព្រះវិហារ។ ថ្ងៃមួយនៅថ្ងៃទីប្រាំពីរនៃសប្តាហ៍ ព្រះយេស៊ូវទ្រង់បានយាងទៅព្រះវិហារដើម្បីបង្រៀន។ មេដឹកនាំសាសនាក៏នៅទីនោះដែរ។ ពួកគេតែងតែស្វែងរកវិធីដើម្បីចាប់កំហុសព្រះយេស៊ូវ បើមិនគោរពតាមច្បាប់សាសនាយូដា។ មានបុរសម្នាក់នៅក្នុងព្រះវិហារ ដែលដៃស្តាំរបស់គាត់ខូច ។ អ្នកដឹកនាំសាសនាបានគិតអំពីច្បាប់របស់ពួកគេ ដែលបានចែងថា ពួកគេមិនត្រូវធ្វើការនៅថ្ងៃទី ៧ នៃសប្តាហ៍នោះទេ ។ ព្រះយេស៊ូវមានព្រះបន្ទូលទៅបុរសនោះថា៖ «ចូរមកទីនេះ»។ ព្រះយេស៊ូវជ្រាបពីគំនិតរបស់ពួកអ្នកដឹកនាំសាសនា។ ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ «នៅថ្ងៃទីប្រាំពីរតើយើងត្រូវប្រព្រឹត្តអំពើអាក្រក់ឬអំពើល្អ? ព្រះយេស៊ូវបានងាកទៅបុរស ដែលខូចដៃនោះហើយប្រោសព្យាបាលគាត់ឱ្យជាសះស្បើយ ។ អ្នកដឹកនាំខឹងខ្លាំងណាស់! ប៉ុន្តែព្រះយេស៊ូវទ្រង់បានយកចិត្តទុកដាក់ចំពោះការព្យាបាលដៃរបស់បុរសនោះ ច្រើនជាងបារម្ភណ៍ពីអ្វីដែលអ្នកដឹកនាំសាសនាគិត។

ព្រះយេស៊ូវទ្រង់បានប្រោសព្យាបាលមនុស្សសាមញ្ញ និងមនុស្សសំខាន់ៗ។ វាមិនសំខាន់ថា អ្នកជានរណាទេចំពោះ. ព្រះយេស៊ូវនោះ។ ទ្រង់មានចិត្តល្អចំពោះមនុស្សគ្រប់គ្នា។ ថ្ងៃមួយទ្រង់យាងទៅក្រុងកាពើណិម ។ នៅទីនោះមាននាយទាហានម្នាក់ដែលអ្នកបម្រើរបស់គាត់កំពុងឈឺ។ នាយទាហានគឺជាបុរសសំខាន់ម្នាក់។ គាត់បានដឹកនាំទាហាននៅក្នុងទីក្រុងនោះ។ អ្នកបម្រើម្នាក់របស់នាយទាហាននោះឈឺខ្លាំង។ មិត្តភក្តិរបស់នាយទាហានខ្លះចូលមកគាល់ព្រះយេស៊ូវហើយទូលថា៖ "នាយទាហានគឺជាមនុស្សល្អ ។ គាត់ស្រឡាញ់ទីក្រុងរបស់យើង ។ គាត់ស្រឡាញ់ប្រជាជនរបស់យើង ។ សូមទ្រង់អញ្ជើញព្យាបាលអ្នកបម្រើគាត់ផង" ។

ព្រះយេស៊ូវក៏យាងទៅផ្ទះនាយទាហាននោះ។ ប៉ុន្តែមុនពេលដែលព្រះយេស៊ូទៅដល់ទីនោះនាយទាហានបានប្រាប់មិត្តខ្លះរបស់គាត់ថា "ចូរប្រាប់ព្រះយេស៊ូវថា ទ្រង់មិនចាំបាច់មកដល់ឯផ្ទះខ្ញុំទេ។ ខ្ញុំយល់ពីប្រសិទ្ធភាពរបស់អាជ្ញាធរ។ អ្វីដែលព្រះយេស៊ូវត្រូវធ្វើគឺគ្រាន់តែមានបន្ទូល នោះអ្នកបម្រើរបស់ខ្ញុំនឹងជាសុខសប្បាយជាមិនខាន"។ ព្រះយេស៊ូវស្ងប់ស្ងែង ចំពោះជំនឿរបស់នាយទាហាននោះណាស់។ អ្នកបម្រើរបស់គាត់ក៏បានជាសះស្បើយទាំងស្រុងទៅ។ នៅថ្ងៃមួយព្រះយេស៊ូវទ្រង់កំពុងបង្រៀននៅក្បែរសមុទ្រ។ ក្នុងអំឡុងពេលនោះលោកយ៉ៃរ៉ូសដែលជាអ្នកដឹកនាំសាសនាម្នាក់បានលុតជង្គង់នៅទៀបព្រះបាទា របស់ព្រះយេស៊ូវ ហើយបានអង្វរព្រះអង្គឱ្យព្យាបាលកូនស្រីតូចរបស់គាត់ផង ។ នាងឈឺធ្ងន់ជិតស្លាប់ហើយ។ នៅពេលដែលព្រះយេស៊ូវធ្វើដំណើរទៅផ្ទះលោកមានអ្នកនាំសារម្នាក់មកដល់ ហើយប្រាប់លោកយ៉ៃរ៉ូសថា៖ «កុំរំខានព្រះយេស៊ូវទៀតអី កូនស្រីរបស់លោកបានស្លាប់បាត់ទៅហើយ ។

ព្រះយេស៊ូវទ្រង់មានបន្ទូលទៅលោកយ៉ៃរ៉ូសថា "កុំបារម្ភអី គ្រាន់តែមានជំនឿទៅបានហើយ" ព្រះយេស៊ូវ និងសាវ័ក មានលោកពេត្រុស លោកយ៉ាកុប និងលោកយ៉ូហានបានទៅផ្ទះយ៉ៃរ៉ូស។ មានសមាជិកគ្រួសារ និងមិត្តភក្តិជាច្រើនកំពុងតែយំដោយសារតែកូនស្រីរបស់គាត់បានស្លាប់។ ព្រះយេស៊ូវមានព្រះបន្ទូលថាៈ ក្មេងនេះមិនទាន់ស្លាប់ទេ នាងគ្រាន់តែដេកលក់ទេតើ ។ មនុស្សគ្រប់គ្នាសើចចំអកដាក់ទ្រង់។ ទ្រង់បានឲ្យពួកគេចេញទៅទាំងអស់ លើកលែងតែពួកសិស្សរបស់ទ្រង់ និងឪពុកម្តាយរបស់ក្មេងនោះ។ ទ្រង់ក៏ចូលទៅក្នុងបន្ទប់ដែលក្មេងនោះដេក ។ ព្រះយេស៊ូវចាប់ដៃនាងហើយមានបន្ទូលថា៖ «ក្មេងតូចអើយ! ចូរក្រោកឡើង»។ ភ្លាមៗនោះនាងក្រោកឈរឡើង ហើយដើរ។ នាងមានអាយុដប់ពីរឆ្នាំ។ ព្រះយេស៊ូវមានបន្ទូលថា ចូរយកអាហារឱ្យនាងបរិភោគផង។ មនុស្សគ្រប់គ្នាមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង!

**លូកា ៦-៧ ម៉ាកុស ៥**

## 3.10 ព្រះយេស៊ូវព្យាបាលមនុស្សថែមទៀត
## សេចក្តីណែនាំសម្រាប់គ្រូបង្រៀន កំណត់សំគាល់

១) ព្រះយេស៊ូវបានព្យាបាលជំងឺគ្រប់ប្រភេទ ។ ទ្រង់អាចព្យាបាលរាងកាយ និងអាចព្យាបាលចិត្តគំនិតបាន ។ ព្រះយេស៊ូវអាចបញ្ជាឱ្យពួកដេីរតាមអារក្ស ឱ្យចេញពីមនុស្សហេីយពួកវានឹងធ្វេីតាមទ្រង់ ។

២) ព្រះយេស៊ូវគង់នៅក្នុងព្រះវិហារនៅថ្ងៃទី៧ នៃសប្តាហ៍។ មានបុរសម្នាក់ដែលនៅទីនោះដៃរបស់គាត់បានខូច។ មេដឹកនាំសាសនាបានដឹងថាច្បាប់យូដារបស់ពួកគេបានចែងថាមិនត្រូវធ្វេីនៅថ្ងៃទី៧ឡេីយ។ ប៉ុន្តែព្រះយេស៊ូវបានព្យាបាលបុរសនោះ។ ព្រះយេស៊ូវទ្រង់បានយកចិត្តទុកដាក់ ចំពោះការព្យាបាលដៃរបស់បុរសនោះច្រេីនជាង បារម្ភណ៍ពីអ្វីដែលអ្នកដឹកនាំសាសនាគិត

៣) ព្រះយេស៊ូវគង់នៅក្រុងកាពើណិម ។ អ្នកបម្រេីរបស់នាយទាហានម្នាក់ឈឺ ។ មិត្តភក្តិរបស់នាយទាហាននោះបានសុំឱ្យព្រះយេស៊ូវយាងទៅប្រោសអ្នកបម្រេីនោះ។ ប៉ុន្តែនាយទាហានបាននិយាយថា ព្រះយេស៊ូវមិនចាំបាច់យាងមកឯផ្ទះរបស់គាត់ទេ។ គាត់ដឹងថាអ្វីដែលព្រះយេស៊ូវត្រូវធ្វេីគឺគ្រាន់តែមានបន្ទូល នោះអ្នកបម្រេីរបស់គាត់នឹងបានជាសះស្បេីយជាមិនខាន។ ព្រះយេស៊ូវបានភ្ញាក់ផ្អើលយ៉ាងខ្លាំងចំពោះជំនឿរបស់នាយទាហាននោះ។ អ្នកបម្រេីរបស់គាត់ក៏បានជាសះស្បេីយទៅ ។

៤) នៅថ្ងៃមួយពេលព្រះយេស៊ូវកំពុងតែបង្រៀន មានបុរសម្នាក់ឈ្មោះយ៉ៃរ៉ូសចូលមកជិតទ្រង់។ គាត់បានអង្វរព្រះយេស៊ូវឲ្យព្យាបាលកូនស្រីរបស់គាត់។ នាងឈឺធ្ងន់ណាស់។ នៅពេលពួកគេទៅដល់ផ្ទះរបស់លោកយ៉ៃរ៉ូសអ្នកនាំសារម្នាក់បានប្រាប់គាត់ថា កូនស្រីរបស់គាត់បានស្លាប់ទៅហេីយ។ ព្រះយេស៊ូវបានប្រាប់លោកយ៉ៃរ៉ូសឲ្យមានជំនឿ។ នៅឯផ្ទះរបស់លោកយ៉ៃរ៉ូសមានមនុស្សជាច្រេីនកំពុងយំ។ ពួកគេសេីចនៅពេលដែលព្រះយេស៊ូវបានប្រាប់ពួកគេថា នាងកំពុងតែដេកលក់ទេ។ ព្រះយេស៊ូវទ្រង់យាងចូលទៅក្នុងផ្ទះ ហេីយចាប់ដៃកូនស្រីរបស់លោកយ៉ៃរ៉ូស។ ទ្រង់ក៏មានបន្ទូលថា "ក្មេងស្រីតូចអេីយ ចូរក្រោកឡេីង!" នាងក៏បានជាសះស្បេីយ។

**សំណួរ**

១) តេីព្រះយេស៊ូវបានព្យាបាលអ្វីខ្លះ?

២) តេីព្រះយេស៊ូវបានធ្វេីអ្វីនៅក្នុងព្រះវិហារ នាថ្ងៃទី ៧ នៃសប្តាហ៍?

៣) ហេតុអ្វីបានជានាយទាហាននិយាយថា ព្រះយេស៊ូវមិនចាំបាច់មកឯផ្ទះ ដេីម្បីព្យាបាលអ្នកបម្រេីរបស់ខ្លួននោះទេ?

៤) តេីលោកយ៉ៃរ៉ូសបានទូលសុំឱ្យព្រះយេស៊ូវឲ្យធ្វេីអ្វី?

៥) ហេតុអ្វីបានជាមនុស្សនៅឯផ្ទះរបស់លោកយ៉ៃរ៉ូស សេីចចំអកដាក់ព្រះយេស៊ូវ?

៦) តេីព្រះយេស៊ូវបានធ្វេីអ្វី នៅពេលទ្រង់យាងចូលក្នុងផ្ទះរបស់លោកយ៉ៃរ៉ូស?

**ចម្លេីយ**

១) ព្រះយេស៊ូវបានព្យាបាលជម្ងឺគ្រប់ប្រភេទ ។ ទ្រង់អាចព្យាបាលរាង្គកាយ និងអាចព្យាបាលចិត្តគំនិតបាន ។ ព្រះយេស៊ូវទ្រង់អាចបញ្ជាឱ្យពួកដេីរតាមអារក្ស ឱ្យចេញពីមនុស្ស ហេីយពួកវានឹងធ្វេីតាមទ្រង់ ។

២) នៅថ្ងៃទី៧ នៃសប្តាហ៍ ព្រះយេស៊ូវទ្រង់បានព្យាបាលបុរសម្នាក់ដែលខូចដៃឲ្យជា ។

៣) នាយទាហានដឹងថាអ្វីដែលព្រះយេស៊ូវទ្រង់ត្រូវធ្វេីគឺគ្រាន់តែមានបន្ទូល នោះអ្នកបម្រេីរបស់គាត់នឹងបានជាសះស្បេីយជាមិនខាន ។

៤) លោកយ៉ៃរ៉ូសបានទូលសូមឲ្យព្រះយេស៊ូវព្យាបាលកូនស្រីរបស់គាត់ ។

៥) មនុស្សនៅឯផ្ទះរបស់លោកយ៉ៃរ៉ូសសេីចចំអកដាក់ព្រះយេស៊ូវ ពីព្រោះទ្រង់បានប្រាប់ពួកគេថាកូនស្រីរបស់លោកយ៉ៃរ៉ូសកំពុងតែដេកលក់ ។

៦) ព្រះយេស៊ូវកាន់ដៃកូនស្រីរបស់លោកយ៉ៃរ៉ូស ហេីយប្រាប់នាងឱ្យក្រោកឡេីង ។ នាងក៏ជាសះស្បេីយទៅ ។



Kids of Destiny®
Reaching the Next Generation

www.kidsofdestiny.org